# បញ្ញត្តិ និងលក្ខខណ្ឌទូទៅនៃគណនីជំនាន់ថ្មី (New Gen Account)

## ១. សេចក្តីផ្តើម

បញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ គឺជាកិច្ចព្រមព្រៀងរវាង "អេ អឹម ខេ" និង "អតិថិជន" និងឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់របស់អតិថិជន។ នៅពេលដែលអតិថិជន និងឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់របស់អតិថិជនបានអាន និង យល់ព្រម បញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ មានន័យថាអតិថិជន និងឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់របស់អតិថិជនព្រមទទួលយក និងអនុវត្តតាមបញ្ញតិ និងលក្ខខណ្ឌទូទៅនៃគណនីជំនាន់ថ្មី នេះ និងបញ្ញត្តិ និងលក្ខខណ្ឌទូទៅផ្សេងទៀតនៃផលិតផល និង/ឬ សេវាកម្មដែលពាក់ព័ន្ធ។

បញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ គឺជាឯកសារដ៏សំខាន់មួយ ដែលលោកអ្នកត្រូវតែអាន និងយល់ឲ្យបានច្បាស់មុននឹងសម្រេចចិត្តប្រើប្រាស់គណនីជំនាន់ថ្មី។ សូមទំនាក់ទំនងមក អេ អឹម ខេ ប្រសិនបើលោកអ្នកមានចម្ងល់ទាក់ទងទៅនឹងបញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ។

តាមរយៈការ "យល់ព្រម" លោកអ្នកបានបញ្ជាក់ថា លោកអ្នកបានអាន បានយល់ច្បាស់ បានទទួលស្គាល់ បានទទួលយក និងបានយល់ព្រមនូវ បញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ។ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ ប្រសិនបើមានបញ្ញត្តិ និងលក្ខខណ្ឌទូទៅផ្សេងទៀត ផ្ទុយនឹងបញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ នោះបញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះត្រូវបានយកជាគោល។

## ២. និយមន័យ

- អេ អឹម ខេ៖ ធនាគារ អេ អឹម ខេ ម.ក (AMK Bank Plc)។
- កុមារ៖ សំដៅលើអនីតិជនដែលមានអាយុចាប់ពី ១២ឆ្នាំ ដល់តិចជាង១៨ឆ្នាំ ដែលមិនមានអត្តាធីនភាពតាមរយៈដីកាសម្រេចពីតុលាការ ឬ ស្ថិតក្រោមវ័យ រៀបការតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- អតិថិជន៖ សំដៅដល់ កុមារ ដែលមានគណនីជំនាន់ថ្មី របស់ អេ អឹម ខេ។
- គណនីជំនាន់ថ្មី (New Gen Account)៖ សំដៅលើប្រភេទគណនីសម្រាប់អនីតិជនដែលបើកតាមកម្មវិធីធនាគារចល័ត អេ អឹម ខេ របស់ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់។ គណនីជំនាន់ថ្មីនឹងត្រូវបើក ក្រោមឈ្មោះអនីតិជនដែលស្ថិតក្រោមការគ្រប់គ្រងរបស់ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់។
- នីតិជន៖ សំដៅដល់បុគ្គលដែលមានអាយុគ្រប់តាមច្បាប់កំណត់ហើយមានសមត្ថភាពឯករាជ្យអាចបំពេញកិច្ចការ ឬប្រតិបត្តការណាមួយដោយខ្លួនឯង។
- លោកអ្នក៖ សំដៅលើ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ របស់អតិថិជន។

## ៣. ការបើកគណនីជំនាន់ថ្មី

លក្ខខណ្ឌអនុញ្ញាតឱ្យឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ធ្វើការបើកគណនីជំនាន់ថ្មី មានដូចខាងក្រោម៖

- ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់របស់កុមារជាអ្នកធ្វើសំណើបើកគណនីជំនាន់ថ្មី ឱ្យកុមារ តាមរយៈកម្មវិធីធនាគារចល័ត អេ អឹម ខេ តែមួយប៉ុណ្ណោះ។
- ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ របស់កុមារ ត្រូវដាក់សំណើសុំបើក គណនីជំនាន់ថ្មី ឱ្យកុមារ ដោយត្រូវផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណរបស់កុមារ និងឯកសារបញ្ជាក់អំពីទំនាក់ទំនង ដែលក្នុងនោះរួមមាន សំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត សៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅ ឬ សេចក្តីសម្រេចរបស់តុលាការ ឬ/និង ឯកសារមានសុពលភាពផ្សេងទៀត ដែលអាចប្រើប្រាស់សម្រាប់ផ្ទៀងផ្ទាត់ ពីទំនាក់ទំនងរវាងឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ និងកុមារ។
- ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ អាចបើកគណនីជំនាន់ថ្មី សម្រាប់កុមារមានអាយុចាប់ពី ១២ ឆ្នាំ ដល់ អាយុតិចជាង ១៨ឆ្នាំ គិតត្រឹមកាលបរិច្ឆេទបើកគណនី។
- ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់មានសិទ្ធិស្របច្បាប់អាចស្នើសុំបើកគណនីជំនាន់ថ្មី ឱ្យកូនៗបានច្រើនបំផុត១០នាក់តែប៉ុណ្ណោះ។
- អតិថិជនម្នាក់អាចមានគណនីពីរ រួមមាន គណនីរូបិយប័ណ្ណខ្មែររៀល និងដុល្លារអាមេរិក។
- រាល់ការបើកគណនីជំនាន់ថ្មីត្រូវបានឆ្លងកាត់ការពិនិត្យ និងអនុម័តពី អេ អឹម ខេ។ អេ អឹម ខេ នឹងធ្វើការជូនដំណឹងអំពីការអនុម័ត ឬ ការបដិសេធក្នុងការបើកគណនីជំនាន់ថ្មីតាមរយៈកម្មវិធីធនាគារចល័ត អេ អឹម ខេ ឬ បណ្តាញផ្សេងៗទៀតដែល អេ អឹម ខេ យល់ឃើញថាសមស្រប។
- អេ អឹម ខេ អាចទាក់ទងទៅ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់របស់អតិថិជន ដើម្បីស្នើសុំព័ត៌មាន ឬ ការបញ្ជាក់បន្ថែម ប្រសិនបើចាំបាច់។
- ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ ត្រូវបានចាត់ទុកថាបានផ្តល់ការយល់ព្រមជាអចិន្ត្រៃយ៍ ក្នុងការផ្តល់ការយល់ព្រមអនុញ្ញាតឱ្យកុមារប្រើប្រាស់គណនីជំនាន់ថ្មីស្របតាមគោលនយោបាយ និងនីតិវិធី របស់ អេ អឹម ខេ។
- ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់របស់អតិថិជន យល់ព្រម និងទទួលស្គាល់ថាឈ្មោះផ្លូវការរបស់គណនីអតិថិជនគឺជាឈ្មោះជាភាសាខ្មែរដូចដែលមានចែងក្នុងឯកសារសម្គាល់ខ្លួនដែលចេញដោយអាជ្ញាធរកម្ពុជា។ ក្នុងករណីដែលឯកសារសម្គាល់ខ្លួនមិនមានឈ្មោះជាភាសាអង់គ្លេស ឬក្នុងករណីដែលអក្ខរាវិរុទ្ធជាភាសាអង់គ្លេសមានកំហុស អេ អឹម ខេ អាចបញ្ចូល ឬកែតម្រូវឈ្មោះជាភាសាអង់គ្លេសជាការសរសេរតាមសូរសព្ទពីឈ្មោះភាសាខ្មែរ ដើម្បីបំពេញតាមតម្រូវការរបស់ប្រព័ន្ធធនាគារស្នូលរបស់ អេ អឹម ខេ។ ក្នុងករណីមានភាពមិនស៊ីសង្វាក់គ្នារវាងភាសាខ្មែរ និងភាសាអង់គ្លេស ឪពុក

ឬម្ដាយ ឬអាណាព្យាបាលស្របច្បាប់យល់ព្រមថាការសរសេរតាមសូរសព្ទ ឬការកែតម្រូវបែបនេះនឹងមិនប៉ះពាល់ដល់សុពលភាពផ្លូវច្បាប់នៃឈ្មោះជាភាសាខ្មែរនោះទេ ដោយឈ្មោះជាភាសាខ្មែរត្រូវយកជាគោល។

- ក្នុងករណី ឪពុក ឬ ម្ដាយ ឬ អាណាព្យាបាលស្របច្បាប់របស់អតិថិជន ផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ និង/ឬ ឯកសារបញ្ជាក់អំពីទំនាក់ទំនង មានសភាពមិនច្បាស់ ឬមិនត្រឹមត្រូវ ឬប្រឡាក់ នោះនាយកដ្ឋានទំនាក់ទំនងសេវាកម្មអតិថិជននឹងធ្វើការទាក់ទងទៅកាន់ ឪពុក ឬ ម្ដាយ ឬ អាណាព្យាបាលស្របច្បាប់របស់អតិថិជន ដើម្បីស្នើសុំផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ និង/ឬ ឯកសារបញ្ជាក់អំពីទំនាក់ទំនងសារជាថ្មី។

## ៤. ប្រតិបត្តិការលើគណនីជំនាន់ថ្មី

- គណនីជំនាន់ថ្មីអាចដំណើរការបានតាមរយៈកម្មវិធីធនាគារចល័ត អេ អឹម ខេ និង តាមបណ្ដាញឌីជីថលដែលបានអនុញ្ញាតតែប៉ុណ្ណោះ។ ប្រតិបត្តិការតាមបញ្ជរ (តាមសាខា) មិនត្រូវបានអនុញ្ញាតឡើយ លើកលែងប្រតិបត្តិការបិទគណនីជំនាន់ថ្មី។
- ឪពុក ឬ ម្ដាយ ឬ អាណាព្យាបាលស្របច្បាប់ ត្រូវកំណត់ប្រភេទប្រតិបត្តិការដែលអនុញ្ញាត និងកម្រិតប្រតិបត្តិការគណនី ហើយកុមារអាចដំណើរការប្រតិបត្តិការលើគណនីជំនាន់ថ្មីបានតែក្នុងកម្រិតដែលបានកំណត់តែប៉ុណ្ណោះ។
- ប្រតិបត្តិការមួយចំនួនលើគណនីជំនាន់ថ្មីត្រូវបានហាមឃាត់ស្របទៅតាមលក្ខណៈផលិតផលដែលមានចែងក្នុងផ្នែកទី ៥នៃបញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ។

## ៥. លក្ខណៈផលិតផល

| លក្ខខណ្ឌ | ការពិពណ៌នា |
|---|---|
| រូបិយប័ណ្ណ | រៀល និង ដុល្លារអាមេរិក |
| អត្រាការប្រាក់ប្រចាំឆ្នាំ | រហូតដល់ ៣,០០% |
| ទឹកប្រាក់ដាក់ដំបូង | មិនតម្រូវ |
| សមតុល្យតម្កល់អប្បបរមា | មិនតម្រូវ |
| ឯកសារបញ្ជាក់កម្មសិទ្ធិគណនី | មិនមាន |
| បណ្ដាញប្រតិបត្តិការ | កម្មវិធីធនាគារចល័ត អេ អឹម ខេ (AMK Mobile Application) និង បណ្ដាញឌីជីថលផ្សេងទៀតរបស់អេ អឹម ខេ |
| កម្រិតប្រតិបត្តិការគណនីជំនាន់ថ្មី កំណត់ដោយ អេ អឹម ខេ | **ប្រភេទប្រតិបត្តិការ** / **អតិបរមាប្រចាំថ្ងៃ** / **អតិបរមាប្រចាំខែ**<br>ប្រតិបត្តិការចូល: • ៤០.០០០.០០០ រៀល និង • ១០.០០០ ដុល្លារអាមេរិក / មិនកំណត់<br>ប្រតិបត្តិការចេញ: • ១.០០០.០០០ រៀល និង • ២៥០ ដុល្លារអាមេរិក / • ១០.០០០.០០០ រៀល និង • ២.៥០០ ដុល្លារអាមេរិក |
| ថ្លៃសេវា | • ការបិទគណនី — មិនគិតថ្លៃ<br>• ការភ្ជាប់សេវាធនាគារចល័ត AMK Mobile — មិនគិតថ្លៃ<br>• ការជូនដំណឹងពត៌មានគណនីតាមរយៈទូរស័ព្ទដៃ — មិនគិតថ្លៃ<br>• គណនីមិនមានសកម្មភាព — សេវាប្រចាំខែ (យោងតាមព័ត៌មានលម្អិតនៅលើបណ្ដាញផ្សព្វផ្សាយរបស់ អេ អឹម ខេ)<br>• កាត — សេវាប្រចាំឆ្នាំ (យោងតាមព័ត៌មានលម្អិតនៅលើបណ្ដាញផ្សព្វផ្សាយរបស់ អេ អឹម ខេ) |
| ប្រតិបត្តិការអនុញ្ញាត | • ដាក់ ឬ ដកប្រាក់ ដោយការស្កេន QR CODE<br>• ដកប្រាក់ជាប្រតិបត្តិការ e-Cash នៅតាមបណ្ដាញប្រតិបត្តិការដែលសមស្រប<br>• ផ្ទេរប្រាក់រវាងគណនីផ្ទាល់ខ្លួន ឬ គណនី អេ អឹម ខេ ផ្សេងទៀត<br>• ផ្ទេរទៅសាច់ប្រាក់<br>• ផ្ទេរប្រាក់ទៅគណនីធនាគារ ឬ គណនីទូទាត់ ក្នុងស្រុកតាមប្រព័ន្ធបាគង<br>• ទទួលប្រាក់ផ្ទេរពីគណនី អេ អឹម ខេ<br>• ទទួលប្រាក់ផ្ទេរពីគណនីធនាគារ ឬ គណនីទូទាត់ ក្នុងស្រុកតាមប្រព័ន្ធបាគង<br>• ទូទាត់តាម KHQR<br>• ទូទាត់វិក្កយបត្រ ទូទាត់ទំនិញ ឬ ទូទាត់ផ្សេងៗ<br>• Deeplink ឬ ប្រតិបត្តិការ E-Commerce<br>• បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ<br>• ស្នើសុំកាតនិម្មិត<br>• ប្រតិបត្តិការផ្សេងៗទៀតដែលមានលើកម្មវិធីធនាគារចល័ត អេ អឹម ខេ និងកំណត់ដោយ អេ អឹម ខេ |

| | |
|---|---|
| ប្រតិបត្តិការហាមឃាត់ | • ស្នើកម្ចី<br>• ទូទាត់កម្ចី<br>• ផ្ទេរប្រាក់ទៅក្រៅប្រទេស<br>• ផ្ទេរប្រាក់ទៅតាមកាត UPI ឬ កាត VISA<br>• ទទួលប្រាក់ផ្ទេរពីក្រៅប្រទេស<br>• ទទួលប្រាក់ផ្ទេរពីកាត UPI ឬ កាត VISA<br>• ស្នើប័ណ្ណឥណពន្ធ (មិនមែនប័ណ្ណនិមិត្ត)<br>• បើកគណនីមានកាលកំណត់ និងគណនីមានកិច្ចសន្យាបន្ថែម<br>• បើកគណនីសន្សំមិនមានកាលកំណត់បន្ថែម<br>• ប្រតិបត្តិការហិរញ្ញវត្ថុទាំងអស់<br>• ស្នើសុំបន្ថែមគំរូហត្ថលេខា ឬ ស្នាមមេដៃ<br>• ស្នើសុំកែប្រែលក្ខខណ្ឌប្រតិបត្តិការ ឬ បិទគណនី |
| សិទ្ធិឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់លើគណនីជំនាន់ថ្មី | • កំណត់កម្រិតប្រតិបត្តិការ (មិនអាចលើសពីកម្រិតដែលបានកំណត់ដោយ អេ អឹម ខេ)<br>• កំណត់ប្រភេទប្រតិបត្តិការអនុញ្ញាត (មិនអាចលើសពីការកំណត់ដោយ អេ អឹម ខេ)<br>• ផ្អាក ឬ បើកដំណើរការគណនីជំនាន់ថ្មីឡើងវិញ<br>• ពិនិត្យសមតុល្យគណនី ប្រវត្តិប្រតិបត្តិការ និងទាញរបាយការណ៍គណនីជំនាន់ថ្មី<br>• បិទគណនី |

## ៦. លក្ខខណ្ឌការផ្លាស់ប្តូរប្រភេទអតិថិជន និង លក្ខខណ្ឌគណនី

- អតិថិជនដែលជាម្ចាស់គណនីជំនាន់ថ្មី ដែលមានអាយុគ្រប់១៨ឆ្នាំ ត្រូវផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួនដែលបានក្លាយជានីតិជនតាមរយៈកម្មវិធីធនាគារចល័ត អេ អឹម ខេ មកកាន់ អេ អឹម ខេ បន្ទាប់ពីទទួលបានសារជូនដំណឹង អំពីការស្នើសុំឱ្យប្តូរពីលក្ខខណ្ឌគណនីជំនាន់ថ្មីទៅជាគណនីសន្សំងាយស្រួលដើម្បីអាចប្រើប្រាស់គណនីដូចអតិថិជនទូទៅដែលជានីតិជន។
- ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ និងអតិថិជន នឹងទទួលបានសារជូនដំណឹងថាគណនីជំនាន់ថ្មីត្រូវបានផ្លាស់ប្តូទៅគណនីសន្សំងាយស្រួលដោយជោគជ័យ។ បន្ទាប់ពីផ្លាស់ប្តូរជាគណនីសន្សំងាយស្រួលរួចរាល់ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់នឹងមិនអាចពិនិត្យ ឬ គ្រប់គ្រងគណនីរបស់អតិថិជនបានទៀតទេ។

## ៧. ការបិទគណនី

- មានតែឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ តែប៉ុណ្ណោះដែលមានសិទ្ធិស្នើបិទគណនីជំនាន់ថ្មីបាន។
- ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់អាចស្នើបិទគណនី នៅតាមសាខា អេ អឹម ខេ ណាមួយក៏បាន។
- គណនីជំនាន់ថ្មីអាចត្រូវបិទ តាមឆន្ទានុសិទ្ធិរបស់ អេ អឹម ខេ ដោយពុំចាំបាច់ជូនដំណឹងទៅអតិថិជន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់របស់អតិថិជន តាមលក្ខខណ្ឌខាងក្រោម៖
  - គណនីមិនបានធ្វើតាមលក្ខខណ្ឌនៃបញ្ញត្តិ និងលក្ខខណ្ឌទូទៅនៃគណនីជំនាន់ថ្មីនេះ។
  - គណនីអសកម្មមិនមានសមតុល្យទឹកប្រាក់ និង មិនមានសកម្មភាពចាប់ពី ៣ឆ្នាំឡើងទៅ។
  - គណនីមិនមានសមតុល្យទឹកប្រាក់ និង មិនមានសកម្មភាពចាប់ពី ៩០ថ្ងៃឡើងទៅ គិតចាប់ពីកាលបរិច្ឆេទបើកគណនី។ ឬ
  - បំពានចំណុចណាមួយនៃបញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ និង/ឬលក្ខខណ្ឌផ្សេងទៀតដែល អេ អឹម ខេ បានចែង។

## ៨. សុវត្ថិភាពគណនី

ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ យល់ព្រមទទួលខុសត្រូវ និងបង្ការចំពោះការប្រើប្រាស់ណាមួយដែលគ្មានការអនុញ្ញាត និងទទួលខុសត្រូវក្នុងការចូលប្រើកម្មវិធីធនាគារចល័ត អេ អឹម ខេ លើទូរស័ព្ទចល័តរបស់អតិថិជនដើម្បីការពារព័ត៌មានផ្ទាល់ខ្លួន និងអត្តសញ្ញាណសុវត្ថិភាពរបស់អតិថិជនគ្រប់ពេលវេលា និងបង្ការការខាតបង់ហិរញ្ញវត្ថុដែលបណ្តាលមកពីការលួចអត្តសញ្ញាណសុវត្ថិភាពរបស់អតិថិជនផងដែរ។

## ៩. លក្ខខណ្ឌគណនីត្រូវបានបង្កក និង ការបញ្ឈប់ការបង្កកគណនី

- ករណីដែលឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ ឬ អតិថិជនមិនសហការក្នុងការផ្តល់ឯកសារដើម្បីផ្លាស់ប្តូរលក្ខខណ្ឌពីគណនីជំនាន់ថ្មីទៅគណនីសន្សំងាយស្រួល គណនីជំនាន់ថ្មីទាំងអស់នឹងត្រូវបានបង្កក នៅពេលដែលអតិថិជនដែលជាម្ចាស់គណនីជំនាន់ថ្មីមានអាយុគ្រប់១៩ឆ្នាំ រហូតដល់មានការសហការពីអតិថិជន ឬ រហូតដល់ពេលបិទគណនី។
- អតិថិជនដែលជាម្ចាស់គណនីជំនាន់ថ្មីអាចស្នើសុំផ្លាស់ប្តូរគណនីជំនាន់ថ្មីទៅគណនីសន្សំងាយស្រួលតាមរយៈកម្មវិធីធនាគារចល័តរបស់ អេ អឹម ខេ ឬ មកកាន់ការិយាល័យ អេ អឹម ខេ ព្រមទាំងធ្វើការផ្តល់ជូនឯកសារបញ្ជាក់អត្តសញ្ញាណ មកកាន់ អេ អឹម ខេ នោះអេ អឹម ខេ នឹងបញ្ឈប់ការបង្កកគណនីជំនាន់ថ្មីទាំងអស់ បន្ទាប់ពីការផ្លាស់ប្តូរជោគជ័យ។

- គណនីជំនាន់ថ្មីនឹងត្រូវបានបង្កក ក្នុងករណីមានការស្នើសុំពីអតិថិជន ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ ឬ ស្របតាមការស្នើសុំពីអាជ្ញាធរសមត្ថកិច្ច ឬ មានការសង្ស័យណាមួយទាក់ទងនឹងការសំអាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬ បទល្មើសព្រហ្មទណ្ឌ ឬ បទល្មើសផ្សេងៗណាមួយ រហូតដល់មានការស្នើ ឬ បង្គាប់បញ្ជាថ្មីពីអ្នកស្នើបង្កក។
- អតិថិជន និង/ឬឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ យល់ព្រមចូលរួមសហការ និងផ្តល់នូវឯកសារគាំទ្រនានា ដែលពាក់ព័ន្ធនឹងគណនីជំនាន់ថ្មី ឬ ប្រតិបត្តិការរបស់អតិថិជន ប្រសិនបើមានការតម្រូវពី អេ អឹម ខេ ឬច្បាប់ ឬបទបញ្ជា ឬបទប្បញ្ញត្តិផ្សេងរបស់ធនាគារជាតិនៃកម្ពុជា ឬតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីដែលអតិថិជន និង/ឬឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់មិនបានចូលរួមសហការ ឬមិនផ្តល់ឯកសារតាមការស្នើសុំ នោះគណនីជំនាន់ថ្មីទាំងអស់នឹងត្រូវបានបង្កក។

## ១០. មរណភាពរបស់ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់

- ករណីឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ដែលមានសិទ្ធិគ្រប់គ្រងលើគណនីជំនាន់ថ្មីរបស់អតិថិជនបានទទួលមរណៈភាព នោះឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ដែលនៅរស់រានមានជីវិតត្រូវមកកាន់បញ្ជរ (សាខា) ដោយភ្ជាប់ជាមួយឯកសារបញ្ជាក់អំពីទំនាក់ទំនងរវាងខ្លួន និងបុគ្គលដែលបានទទួលមរណៈភាព ដែលអាចប្រើសម្រាប់ផ្ទៀងផ្ទាត់ពីទំនាក់ទំនង ដើម្បីស្នើសុំផ្លាស់ប្តូរគណនីជំនាន់ថ្មី មកក្រោមការគ្រប់គ្រងរបស់ខ្លួន ឬ ស្នើបិទគណនី ស្របតាមដំណើរការនីតិវិធីរបស់ អេ អឹម ខេ។

## ១១. ការរក្សាសិទ្ធិរបស់អេ អឹម ខេ

- អេ អឹម ខេ រក្សាសិទ្ធិក្នុងការផ្លាស់ប្តូរ ឬ កែប្រែ លក្ខខណ្ឌផ្សេងៗដូចបានរៀបរាប់ខាងលើ។
- អេ អឹម ខេ នឹងជម្រាបជូនលោកអ្នកពីការផ្លាស់ប្តូរ ឬ ការកែសម្រួលលក្ខខណ្ឌផ្សេងៗលើគណនីជំនាន់ថ្មីតាមបណ្តាញនានារបស់ អេ អឹម ខេ។

## ១២. ច្បាប់គ្រប់គ្រង

- បញ្ញត្តិ និងលក្ខខណ្ឌទូទៅនៃគណនីជំនាន់ថ្មី នេះ ត្រូវបានគ្រប់គ្រង និងបកស្រាយតាមបទបញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។
- ក្នុងករណីដែលមានភាពមិនត្រូវគ្នារវាងភាសាខ្មែរ និងភាសាអង់គ្លេសនៃលក្ខខណ្ឌទូទៅនៃគណនីជំនាន់ថ្មីនេះ ភាសាខ្មែរ ត្រូវយកជាគោល។
- ក្នុងករណីមានជម្លោះ ឬ ការអះអាងណាមួយកើតឡើង ឬ ពាក់ព័ន្ធនឹងបញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ រវាងអតិថិជន និង/ឬឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ ជាមួយ អេ អឹម ខេ នឹងត្រូវដោះស្រាយតាមរយៈមជ្ឈមណ្ឌលទំនាក់ទំនងរបស់គ្រឹះស្ថាន អេ អឹម ខេ ដែលមានលេខទំនាក់ទំនងលេខ ០២៣ ២២ ០២ ០២ ឬ១៨០០ ២០០ ២០០ និងដោយអនុលោមទៅតាមគោលនយោបាយ សំណូមពរ និងបណ្តឹងតវ៉ារបស់អតិថិជនមុននឹងបញ្ជូនករណីនេះទៅសមត្ថកិច្ចនៃតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

## ១៣. គណនីដែលបើកនាពេលអនាគត

- អតិថិជន និង/ឬឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ យល់ព្រមថា បញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ រួមជាមួយលក្ខខណ្ឌបន្ថែមណាមួយ ឬ លក្ខខណ្ឌដែលបានកែប្រែ ឬ លុបចោល ឬ ផ្លាស់ប្តូរណាមួយ ត្រូវប្រើប្រាស់ចំពោះគណនីជំនាន់ថ្មីដែលអតិថិជន និង/ឬឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ អាចនឹងមានជាមួយ អេ អឹម ខេ នៅថ្ងៃអនាគតផងដែរ។

## ១៤. ការឯកភាពរបស់ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់

- ខ្ញុំជាឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់របស់អតិថិជន បានអាន យល់ និងយល់ស្របអំពីបញ្ញត្តិ និងលក្ខខណ្ឌទូទៅនៃគណនីជំនាន់ថ្មី ដែលមានចែងខាងលើ ហើយខ្ញុំជាឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់របស់អតិថិជន យល់ស្រប និងយល់ព្រមថា ការបន្តប្រើប្រាស់គណនីជំនាន់ថ្មីត្រូវចាត់ទុកជាការយល់ស្របជាមួយនឹង បញ្ញត្តិ និងលក្ខខណ្ឌទូទៅនេះ។

## ១៥. ឯកជនភាព និងការរក្សាព័ត៌មានសម្ងាត់

- **អេ អឹម ខេ** នឹងរក្សាការសម្ងាត់អំពីព័ត៌មានគណនីរបស់ **អតិថិជន** ដោយមិនចែករំលែកទៅបុគ្គលណាម្នាក់ដោយមិនមានការយល់ព្រមពី **អតិថិជន**ឡើយ។
- **អតិថិជន** និង/ឬឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ យល់ព្រមឲ្យ **អេ អឹម ខេ** ប្រើប្រាស់ និងចែករំលែកព័ត៌មានគណនី ដល់ក្រុមហ៊ុនមេ ឬ ក្រុមហ៊ុនបុត្រសម្ព័ន្ធ ឬ សាខា ឬ ម្ចាស់ភាគហ៊ុន ឬ អភិបាល ឬ បុគ្គលិក ឬ សវនករ (ខាងក្នុង និងខាងក្រៅ) ឬ ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ផ្សេងទៀត ឬ ភាគីទីបីក្នុងករណីចាំបាច់ណាមួយ ឬ អ្នកផ្គត់ផ្គង់សេវាកម្ម ឬ អ្នកប្រឹក្សាយោបល់របស់ **អេ អឹម ខេ** យកទៅប្រើប្រាស់ដើម្បីរៀបចំទិន្នន័យ ធ្វើកិច្ចការរដ្ឋបាលផ្សេងៗ ស្រាវជ្រាវ ផ្សព្វផ្សាយទីផ្សារ និងផ្សេងៗ។
- ចំពោះគណនីរបស់ **អតិថិជន** ណាមួយ ដែលមានភ្ជាប់អត្ថប្រយោជន៍ធានារ៉ាប់រង **អតិថិជន** និង/ឬឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ បានយល់ព្រម អនុញ្ញាតឲ្យចែករំលែកព័ត៌មានរបស់ **អតិថិជន** និងព័ត៌មានគណនីរបស់ **អតិថិជន** ទៅកាន់ក្រុមហ៊ុនធានារ៉ាប់រង ដែលជាដៃគូសហការរបស់ **អេ អឹម ខេ** ក្នុងគោលបំណងផ្តល់អត្ថប្រយោជន៍ធានារ៉ាប់រងជូន**អតិថិជន**។
- **អេ អឹម ខេ** នឹងប្រគល់ព័ត៌មានសម្ងាត់របស់ អតិថិជន និង/ឬឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ ដោយពុំជូនដំណឹងទៅ អតិថិជន និង/ឬឪពុក ឬ ម្តាយ ឬ អាណាព្យាបាលស្របច្បាប់ ទេ ក្នុងករណីដែលមានការស្នើសុំពី ធនាគារជាតិនៃកម្ពុជា ឬ តុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ រដ្ឋាភិបាលបរទេសណាមួយ ស្របតាមច្បាប់ បទប្បញ្ញត្តិ និងកិច្ចព្រមព្រៀងអន្តរជាតិដែលរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានចូលរួមអនុវត្ត និងជាសមាជិក។

## ១៦. ដែនកំណត់នៃការទទួលខុសត្រូវ

- លោកអ្នកយល់ព្រមថា អេ អឹម ខេ នឹងមិនទទួលខុសត្រូវចំពោះការខូចខាត ឬ ការខាតបង់ណាមួយដែលលោកអ្នកទទួលរងនៅពេលដែលសេវាកម្មត្រូវបានផ្អាកជាបណ្ដោះអាសន្ន ដែលបណ្ដាលមកពីកម្មវិធីធនាគារចល័ត អេ អឹម ខេ ជាប់គាំងមិនដំណើរការដូចធម្មតា ឬ អាក់អួលមិនថាបង្កឡើងដោយមូលហេតុណាមួយឡើយ រួមទាំងបញ្ហានៃតំណភ្ជាប់អ៊ីនធើណិត។
- អេ អឹម ខេ នឹងមិនទទួលខុសត្រូវចំពោះអតិថិជន លើភាពមិនពេញលេញ ភាពដែលពុំអាចរកបាន ការកើតមាននូវកំហុស ការរំខាន ការផ្អាក ឬ ការពន្យាពេលណាមួយលើការប្រើប្រាស់គណនីជំនាន់ថ្មី តាមរយៈកម្មវិធីធនាគារចល័ត អេ អឹម ខេ និងមិនកំណត់ចំពោះការផ្ញើជូននូវការរំលឹក ឬការជូនដំណឹង បង្កាន់ដៃ ឬ ការអនុវត្តសេចក្ដីណែនាំពី អេ អឹម ខេ ដែលកត្តាទាំងនេះស្ថិតនៅក្រៅវង្វង់នៃការគ្រប់គ្រងរបស់ អេ អឹម ខេ រួមទាំងបញ្ហានៃតំណភ្ជាប់អ៊ីនធើណិត។
- អេ អឹម ខេ មិនធានា មិនអះអាង ឬ ផ្ដល់លក្ខខណ្ឌមួយណាដោយការសម្ដែងចេញដោយផ្ទាល់ ឬ ដោយប្រយោល រួមទាំងការធានាលើគោលបំណងជាក់លាក់ណាមួយ ឬ ការបំពេញកាតព្វកិច្ចណាមួយ ពាក់ព័ន្ធនឹងការប្រើប្រាស់គណនីជំនាន់ថ្មី នោះឡើយ។
- អេ អឹម ខេ មិនទទួលខុសត្រូវចំពោះឧប្បត្តិហេតុណាមួយ ឬ ការខូចខាតដោយផ្ទាល់ ឬ ដោយប្រយោលណាមួយ (រួមបញ្ចូលនិងមិនកំណត់ចំពោះការបាត់បង់ប្រាក់ចំណូល ឬ ការប្រើប្រាស់) ឬ ការខូចខាតតាមច្បាប់ណាមួយដែលកើតចេញពី ឬ ទាក់ទងនឹងលក្ខខណ្ឌនៃការប្រើប្រាស់គណនីជំនាន់ថ្មី។ ក្នុងករណីណាក៏ដោយ អេ អឹម ខេ ពុំមានទំនួលខុសត្រូវចំពោះការចូលប្រើប្រាស់គណនីជំនាន់ថ្មីតាមរយៈកម្មវិធីធនាគារចល័ត អេ អឹម ខេ ដោយអតិថិជនផ្ទាល់ ឬ ដោយភាគីទីបីណាម្នាក់ដោយគ្មានការអនុញ្ញាត ដើម្បីធ្វើការផ្លាស់ប្ដូរ លួច ឬ បំផ្លាញព័ត៌មាននៅក្នុងកម្មវិធីធនាគារចល័ត អេ អឹម ខេ របស់លោកអ្នក ទោះបីដោយចៃដន្យ ឬ ដោយការភាន់ច្រឡំ ឬ ដោយការក្លែងបន្លំ ឬ តាមវិធីណាមួយ ឬ ជាលទ្ធផលណាមួយ ដែលបណ្ដាលមកពីការពន្យាពេល ឬ កំហុសដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ អេ អឹម ខេ នោះទេ៕